ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៦៥

ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០១

សាលដីកា

លេខ : ៤៥

ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣

# នាមនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធានក្រុមប្រឹក្សាជំនុំជំរះ

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ជីវ កេង ចៅក្រម

៤- លោក ប៉ែន សាវឿន ចៅក្រម

៥- លោក សោម សិរីវឌ្ឍ ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក ឈាង វិន្ធា

តំណាងមហាអយ្យការ

លោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ៣១ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០១ របស់ឈ្មោះ ក្រូច មន ដែលប្តឹងមិនសុខចិត្ត ពីសាលដីកាព្រហ្មទណ្ឌលេខ៦៧ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និងសំណុំរឿងព្រហ្មទណ្ឌលេខ ៦៥ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០១ របស់តុលាការកំពូល ។

**<u>ចំពោះ</u>** :ឃាដកម្មគិតទុកជាមុន ប្រព្រឹត្តនៅខេត្តកំពង់ធំ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៧ តាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះ ក្រូច មន ( ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនិង ទីលំនៅសព្វថ្ងៃមុនចាប់ខ្លួននៅភូមិត្បូងក្រពើ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ ប្រពន្ធឈ្មោះ អ៊ាប អ៊ិន មានកូន០៤នាក់ ឪពុកឈ្មោះពត់ ម៉េង ( រស់) ម្តាយឈ្មោះចាន់ ឃុិន "រស់" ទោសពីមុនគ្មាន នៅក្នុងឃុំ ។

- មេធាវីលោក ផេង ស៊ីដេត

- ជនរងគ្រោះឈ្មោះ ឡាង វ៉ាន់ ភេទប្រុស "ស្លាប់" ប្រពន្ធឈ្មោះ ឡាង ហ៊ីម

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឡាង ហ៊ីម ផ្ទេរសិទ្ធិអោយឈ្មោះឡុង ណោម (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅសព្វថ្ងៃ ភូមិក្រពើ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ ។

- មេធាវី គ្មាន

តាមពាក្យបណ្តឹងចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៧ របស់ឈ្មោះឡាង ហ៊ីម ប្តឹងពីឈ្មោះ ក្រូច មន ពីបទសម្លាប់កូនខ្លួនកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៧ ។ក្នុងរឿងនេះខ្លួនប្តឹងសុំទាមទារជម្ងឺចិត្ត៤.០០០ដុល្លារ "បួនពាន់ដុល្លាអាមេរិក" និងផ្តន្ទាទោសតាមច្បាប់ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តកំពង់ធំថា : ចោទប្រកាន់ក្រូច មន អាយុ៣៤ឆ្នាំ ជាតិខ្មែរ មានកំណើតនិងទីលំនៅសព្វថ្ងៃនៅភូមិត្បូងក្រពើ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ របររកស៊ីធ្វើស្រែ ប្រពន្ធឈ្មោះអ៊ាម អ៊ិន មានកូន០៤នាក់ ពីបទ : ឃាដកម្មគិតទុកជាមុន ប្រព្រឹត្តនៅខេត្តកំពង់ធំកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៧ តាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១៣១ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ធំ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ផ្តន្ទាទោសឈ្មោះក្រូច មន អាយុ៣៤ឆ្នាំ ដាក់ពន្ធនាគារកំណត់១២ឆ្នាំ ។ ពីបទ : ឃាដកម្មគិតទុកជាមុនប្រព្រឹត្តនៅភូមិត្បូងក្រពើ ឃុំកកោះស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៧ ។

បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តកាល ។ ទោសខាងលើនេះគិតពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៧ ជាថ្ងៃចាប់ខ្លួនតទៅ ។

២-វត្ថុតាងដែលជាមធ្យោបាយ ប្រព្រឹត្តល្មើសមានកាំបិទុផ្គាក់មួយដងឫស្សីប្រវែង ៦ ដ.ម ត្រូវរឹបអូសបំផ្លាញចោល ។

៣-បង្គាប់អោយឈ្មោះក្រូច មន ជូសជុលជម្ងឺចិត្តជាប្រាក់បីលានរៀលគត់ អោយទៅឈ្មោះឡុង ណោម ជាដើមបណ្តឹងរដ្ឋប្បវេណីទាមទារលើសពីនេះលើកចោល ។

ក្នុងករណីឈ្មោះ ក្រូច មន រឹងរូស ឬគ្មានប្រាក់សងទេ ត្រូវអនុវត្តដាក់គុកបង្ខំលើរូបកាយ ដើម្បីទារធនទណ្ឌតាមច្បាប់ ។

៤-សាលក្រមនេះជំនុំជំរះជាសាធារណៈ ប្រកាសចំពោះមុខគូក្តី និង មេធាវីទុកសិទ្ធិប្តឹងឧទ្ធរណ៍កំណត់រយៈពេលពីរខែ គិតពីថ្ងៃប្រកាសសាលក្រមតទៅ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៥ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់ឈ្មោះក្រូច មន ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១៣១ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៧របស់តុលាការខេត្តកំពង់ធំ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា :សំរេចសុំឱ្យតម្កល់សាលក្រមរបស់តុលាការខេត្តកំពង់ធំទុកជាបានការដដែល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៣៦ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៩៨របស់ឈ្មោះក្រូច មន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹង គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៣១ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ធំ ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងទាស់ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០ របស់ឈ្មោះក្រូច មន ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១៣៦ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : ជនល្មើស និង ជនរងគ្រោះមានគំនុំ និងគ្នា ហើយពេលកើតហេតុជនល្មើស និង ជនរងគ្រោះមានអាវុធដូចគ្នា ហេតុនេះសុំតំកល់សាលក្រមតុលាការថ្នាក់ក្រោមដដែល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៦៧ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០១ របស់សាលា-ឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០ របស់ឈ្មោះក្រូច មន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ១៣៦ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារជន ជាប់ចោទ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីតែទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០១របស់ឈ្មោះក្រូច មន ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៦៧ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញលិខិតបង្គាប់អោយធ្វើសារណា ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ របស់តុលាការ កំពូលបង្គាប់អោយឈ្មោះក្រូច មន ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើសារណាការពារផលប្រយោជន៏របស់ ខ្លួនហើយឈ្មោះនេះបានទទួលនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ រួចហើយប៉ុន្តែមិនបានធ្វើសារណា តាមកំណត់ច្បាប់ទេ ដែលជាហេតុធ្វើអោយគ្មានសារណាឆ្លើយតបរបស់ចុងបណ្តឹងសាទុក្ខតាមកំណត់ ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៏

- បានស្តាប់សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ អមតុលាការកំពូលថា :

+មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះក្រូច មន បានប្រព្រឹត្តបទល្មើសឃាដកម្ម គិតទុកជាមុននៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៧ នៅភូមិត្បូងក្រពើ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ ធំ ពិតប្រាកដមែន ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៣១ នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាល ។

+តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៦៧ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០១ របស់សាលា ឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

បានស្តាប់ចម្លើយរបស់ឈ្មោះក្រូច មន នៅពេលសវនាការថា : បានជាខ្លួនប្តឹងសាទុក្ខ ព្រោះ មុនពេលកើតហេតុខ្លួនបានមិត្តភ័ក្របីនាក់មកស៊ីផឹកនៅផ្ទះ ពេលស៊ីផឹករួចអ្នកទាំងបីក៏បានវិលត្រឡប់ ទៅផ្ទះរបស់គេរៀង១ខ្លួនអស់ ។ បន្តិចក្រោយមកខ្លួន បានឃើញឈ្មោះ វ៉ាន់ ដើរមករកជើងខ្លាំង ខ្លួន ក៏និយាយថា គ្មានជើងខ្លាំងទេ ពេលនោះជនរងគ្រោះក៏ស្ទុះមកវៃខ្លួន១ ក៏ទាញបានកាំបិតនៅក្រោម ផ្ទះគ្រវ៉ាសត្រូវជនរងគ្រោះ ដោយគ្មានចេតនាសម្លាប់នោះទេ ។ ឯកន្លែងជនរងគ្រោះត្រូវកាំបិតស្លាប់ នោះគឺនៅ ជណ្តើរផ្ទះរបស់ខ្លួនដោយមិនបានឃើញកូនកាំបិតទេ ។

- ក្រឡាបញ្ជីអានសារតាជាតិដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឡុង លោម ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក ផេង ស៊ីដេក ជាមេធាវីអោយជនជាប់ចោទ នៅពេលសវនាការថា ៖ សុំអោយតុលាការកំពូលកែប្រែបទចោទ ពីបទឃាតកម្មគិតទុកជាមុនមក ជាបទមនុស្សឃាតដោយចេតនា និងផ្តន្ទាទោសតាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- តំណាងមហាអយ្យការពុំមានយោបល់អ្វីបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានរបស់ខ្លួន ទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវី ជនជាប់ចោទ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០១ របស់ឈ្មោះ ក្រូច មន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានដោយយោង តាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងច្បាស់លាស់គ្រប់គ្រាន់ដែលបញ្ជាក់ថា ឈ្មោះក្រូច មន បាន ប្រព្រឹត្តបទល្មើសឃាតកម្មគិតទុកជាមុន មកលើឈ្មោះឡាង វ៉ាន់ នៅភូមិត្បូងក្រពើ ឃុំកកោះ ស្រុក សន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៧ ដែលបញ្ញត្តិ អោយផ្តន្ទាទោសតាមមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- យល់ឃើញថា ការដែលជនជាប់ចោទលើកឡើងនាពេលសវនាការនេះថា ជនរងគ្រោះបាន មកបង្កហេតុដល់ជណ្តើរផ្ទះរបស់ខ្លួន បានជាខ្លួនកាប់តបវិញ ហើយមេធាវីជនជាប់ចោទសុំអោយ តុលាការកំពូលកែប្រែបទចោទពីបទឃាតកម្មគិតទុកជាមុន មកជាបទមនុស្សឃាតដោយចេតនា និងផ្តន្ទាទោសតាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះពុំមាន សាក្សីណាបញ្ជាក់ថា ជនរងគ្រោះមកបង្ករហេតុដល់ជណ្តើរផ្ទះជនជាប់ចោទទេ មានតែសាក្សីដែល បានឃើញផ្ទាល់ថា ជនជាប់ចោទបានកាប់ជនរងគ្រោះនៅតាមផ្លូវពីក្រោយខ្នង ដោយជនរងគ្រោះពុំ បានដឹងខ្លួនមុនទេ ។ ហើយនៅពេលសវនាការនេះជនជាប់ចោទបានបញ្ជាក់ថា ខ្លួនពុំបានឃើញកូន កាំបិតស្នៀតរបស់ជនរងគ្រោះដូចចម្លើយដែលខ្លួនឆ្លើយនៅតុលាការខេត្តកំពង់ធំថា ជនរងគ្រោះយក កាំបិតស្នៀតស្ទុះមកចាក់ខ្លួនទើបខ្លួនកាប់ជនរងគ្រោះ ។

៦

- យល់ឃើញថា តាមច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ តុលាការអាចដាក់គុកបង្ខំលើរូបកាយ ដើម្បីទារធនទណ្ឌបានតែក្នុងករណីដែលរឹងរូសប៉ុណ្ណោះ ពុំអាចដាក់គុកបង្ខំទារធនទណ្ឌបានក្នុងករណីគ្មានប្រាក់សងបានទេ ដូច្នេះតុលាការកំពូលគប្បីលុបចេញនូវពាក្យ "ឬគ្មានប្រាក់សងទេ" ក្នុងចំណុចទី៣នៃសាលក្រមលេខ១៣១ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ធំ ដោយឥតបង្អិល ។

- យល់ឃើថា ដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលដីកាកោះអោយមកចូលរួមនាសវនាការនេះហើយ ប៉ុន្តែពុំបានមកចូលរួមទេ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៦៧ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ លើកលែងតែពាក្យ "ឬគ្មានប្រាក់សងទេ" ក្នុងចំណុចទី៣ នៃសាលក្រមរបស់តុលាការខេត្តកំពង់ធំ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដីចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹង**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្ដឹងសាទុក្ខលេខ៣១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០១ របស់ឈ្មោះ ក្រូច មន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៦៧ ចុះថ្ងៃទី០៧ ខែមីនាឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការលើកលែងតែពាក្យ"ឬគ្មានប្រាក់សងទេ" ក្នុងចំណុចទី៣ នៃសាលក្រមរបស់តុលាការខេត្តកំពង់ធំ ដែលត្រូវទុកជាមោឃៈដោយឥតបង្អិល ។

៣- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ។